**ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម**

# បច្ចេកទេសផលិតជីកំប៉ុស្ត និងថ្នាំកសិកម្មធម្មជាតិ



**រៀបចំដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ**
**នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម**

**ឧបត្ថម្ភការបោះពុម្ព** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ឆ្នាំ២០១៧**



# សៀវភៅ

# ស្តីពី

# បច្ចេកទេសផលិតជីកំប៉ុស្ត

# និងថ្នាំកសិកម្មធម្មជាតិ

## រៀបចំដោយ


នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ

នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម



បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



រក្សាសិទ្ធដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្ដីពីបច្ចេកទេសផលិតជីកំប៉ុស្ដនិងថ្នាំកសិកម្មធម្មជាតិ

I. ទីប្រឹក្សាផ្ដល់យោបល់:

| | | |
|---|---|---|
| ១. បណ្ឌិត | **ហ៊ាន វណ្ណហាន** | អគ្គនាយកដ្ឋានកសិកម្ម |
| ២. បណ្ឌិត | **ម៉ៅ មិនា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៣. លោក | **ប៉ែន ឧុទ្ធី** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៤. លោក | **គឹម ដារ៉ា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |

II. អ្នករៀបរៀង:

| | | |
|---|---|---|
| ១. លោក | **ផាន ទូច** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |

III. អ្នកស្រាវជ្រាវ:

| | | |
|---|---|---|
| ១. លោក | **វ៉ាន គឹមជាង** | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ |

IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

| | | |
|---|---|---|
| ១. លោក | **ជួង អ៊ាង** | នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ២. លោក | **អ៊ី ឈិន** | នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ៣. លោក | **ហ៊ុង ទ្រី** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៤. លោក | **ឈុន សុភ័ក្រ្ត** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |



## មាតិកា

ទំព័រ


១. សេចក្តីផ្តើម.......................................................................... ០១

២. ការផលិតជីកំប៉ុស្តគោក......................................................... ០២

២.១ វិធីសាស្ត្រនៃការផលិតជីកំប៉ុស្តគោក.................................... ០២

៣. ការផលិតជីកំប៉ុស្តទឹក............................................................. ១១

៣.១ វិធីសាស្ត្រនៃការផលិតជីកំប៉ុស្តទឹក....................................... ១១

៣.២ ការប្រើប្រាស់ជីកំប៉ុស្តទឹក..................................................... ១៣

៤. ការផលិតជីកំប៉ុស្តទ្រុង.............................................................. ១៤

៤.១ របៀបធ្វើទ្រុងជីកំប៉ុស្ត........................................................... ១៤

៥. ការផលិតថ្នាំកសិកម្មធម្មជាតិ..................................................... ២១

៥.១ រុក្ខជាតិដែលអាចយកមកផ្សំជាថ្នាំកសិកម្មធម្មជាតិ...................... ២១

៥.២ វិធីប្រើប្រាស់ថ្នាំកសិកម្មធម្មជាតិ............................................ ២៥

## ១. សេចក្តីផ្តើម

ដីខ្សត់ជីជាតិ នៅតែជាកត្តាចម្បង នៅប្រទេសកម្ពុជានៅឡើយ ដែលជាហេតុនាំឱ្យទិន្នផលដំណាំ នៅមានកម្រិតទាប។ ការសឹករិចរិល នៃជីជាតិដីបណ្តាលមកពី៖

- ការហូរច្រោះនៃដី
- ការប្រើប្រាស់ជីធម្មជាតិនៅមានកម្រិតទាប
- ការប្រើប្រាស់ជីគីមីមិនត្រឹមត្រូវតាមបច្ចេកទេស
- ការដាំដំណាំដដែលៗតែមួយមុខ

នៅក្នុងធម្មជាតិ រុក្ខជាតិនានា និងពពួកសត្វទាំងឡាយដែលបានងាប់ហើយរលួយដោយសារពពួកមីក្រូសារពាង្គកាយ (ផ្សិត បាក់តេរី វីរុស ។ល។) ដោយមានជំនួយពីទឹក ពន្លឺព្រះអាទិត្យ ខ្យល់ និងពេលវេលា ។ ដំណើរការពុកផុយនៃសារធាតុសរីរាង្គ (រុក្ខជាតិ និងពពួកសត្វ) បង្កើតបានជាសារធាតុចិញ្ចឹមរុក្ខជាតិ និងសារធាតុមមោក ដែលសម្បូរដោយជីជាតិ ដើម្បីផ្តល់ឱ្យដំណាំ និងរុក្ខជាតិនានា សម្រាប់ការដុះលូតលាស់ និងផ្តល់ផ្លែផ្កា។ ជីកំប៉ុស្តបានផ្តល់អត្ថប្រយោជន៍ជាច្រើនដូចជា៖

- ជួយកែលម្អជីជាតិ និងផលិតភាពដី
- ជួយឱ្យដីធូ ងាយស្រួលដល់ការលូតលាស់របស់ដំណាំ និងមានខ្យល់ចេញចូលបានល្អនៅក្នុងដី
- ជួយដីក្នុងការរក្សាទឹក និងជីជាតិ
- បង្កើនសកម្មភាព និងសត្វនៅក្នុងដី
- ជួយបង្កើនទិន្នផល និងគុណភាពផលិតផលដំណាំ
- ជួយជំរុញឱ្យការប្រើប្រាស់ជីគីមី មានប្រសិទ្ធភាពខ្ពស់ នៅពេលប្រើលាយជាមួយជីកំប៉ុស្ត
- បន្ថយជាតិពុលនៃដី

ក្រៅពីគុណប្រយោជន៍ផ្សេងៗគ្នាទាំងនេះ ការប្រើប្រាស់ជីកំប៉ុស្ត ជំនួសជីគីមីបានជួយកាត់បន្ថយការបំពុល និងការខូចខាតបរិស្ថាន និងជួយថែរក្សាប្រភពថាមពលដែលពុំអាចបង្កើតជាថ្មីឡើងវិញបាន។

# ២. ការផលិតជីកំប៉ុស្តគោក

## ២.១ វិធីសាស្ត្រនៃការផលិតជីកំប៉ុស្តគោក

- ពេលវេលានៃការផលិតជីកំប៉ុស្ត អាចធ្វើទៅបាននៅគ្រប់រដូវកាល។

**សម្ភារ**

ក. ឧបករណ៍ប្រើប្រាស់

រទេះគោសម្រាប់ដឹកជញ្ជូន រទេះរុញ លួស ចប ប៉ែល បង្គី កាំបិទ ពូថៅ ធុងទឹក បង្គោលឫស្សី បង្គោល ឈើ ខ្សែចំណង ។ល។













## ខ. វត្ថុធាតុសរីរាង្គ

ប្រមូលវត្ថុធាតុដើមមានដូចជា៖ ស្មៅស្រស់ ចំបើង ដើម និងស្លឹករុក្ខជាតិ ផេះ លាមកសត្វ និងកាកសំណល់ផ្សេងៗពីផ្ទះបាយ។



ស្មៅស្រស់



ដើមរុក្ខជាតិ



លាមកសត្វ



កាកសំណល់ពីក្រោលសត្វ



កាកសំណល់ផ្ទះបាយ



ស្លឹកឈើ



ចំបើង



ផេះ ដីដំបូក និងអង្កាម

## ដំណើរការផលិតជីកំប៉ុស្តគោក

ការធ្វើជីកំប៉ុស្តមានច្រើនរបៀបដូចជា: របៀបធ្វើជីកំប៉ុស្តលើដីរៀបស្មើ របៀបធ្វើកំប៉ុស្តក្នុងរណ្តៅ និងរបៀបធ្វើជីកំប៉ុស្តទឹក។ល។

☛ ការផលិតជីកំប៉ុស្តលើដីរៀបស្មើ

**ជំហានទី១៖** ជ្រើសរើសទីតាំងដែលសមស្រប ជាទីទួល ឬកន្លែងមិនដក់ទឹក នៅជិតរោងចិញ្ចឹមសត្វ គួរជៀសវាងធ្វើពីខាងមុខ ឬជិតជាមួយនឹងផ្ទះពេក។

**ជំហានទី២៖** បោះបង្គោលឫស្សី ឬឈើដែលមានបណ្តោយ ៣ ម និង ទទឹង ២ ម ឬក៏អាចធំជាងនេះ។





ការរៀបចំដីធ្វើជីកំប៉ុស្ត

**ជំហានទី៣៖** ដើម្បីសាងសង់រោងជីត្រូវមាន កូនឈើ ឬដើមឫស្សី ស្លឹកត្នោត

ឬសង្ក័សី ខ្សែធាងត្នោត ដែកគោល ។ល។ ទំហំរោងត្រូវជីកដី បណ្ដោយ៣ម ទទឹង ២ម៉ែត្រ ជម្រៅ ០,៥ ម ធ្វើជញ្ជាំងព័ទ្ធជុំវិញ ដែលមានកម្ពស់០,៥ ម ចាប់ពីមាត់រណ្ដៅឡើងលើ និងប្រក់ដំបូលការពារកម្ដៅថ្ងៃ និងទឹកភ្លៀង។




គំនូសបំព្រួញរោងជីកំប៉ុស្ត



រោងជីកំប៉ុស្ត

**ជំហានទី៤៖** ប្រមូលវត្ថុធាតុផ្សំធ្វើជីកំប៉ុស្ត មានស្លឹកឈើ ចំបើង អង្កាមដីដំបូក លាកមកសត្វកាកសំណល់ផ្សេងៗ ពីផ្ទះបាយ មិនត្រូវដាក់វត្ថុរឹង មិនរលួយចូលក្នុងរណ្ដៅឡើយដូចជា ថង់ប្លាស្ទីក អំបែងដប ដុំថ្ម កំណាត់ឈើ សម្លៀកបំពាក់។



ការដញ្ញាំដើមទន្ទ្រានខេត្រ



ការដាក់វត្ថុធាតុផ្សំនៅបាតរណ្ដៅ

**ជំហានទី៥៖** ក្រាលស្រទាប់ស្មៅ ស្លឹកឈើ ចំបើង និងរុក្ខជាតិផ្សេងៗទៅលើដី ស្រទាប់នេះអាចមានកម្រាស់ ៧-១៥ ស.ម និងត្រូវមានសំណើមជានិច្ច តែមិនត្រូវជោគជាំពេកទេ។







ការក្រាលស្រទាប់ស្មៅ ឬវត្ថុធាតុផ្សេងៗ

**ជំហានទី៦៖** នៅពីលើស្រទាប់ទី១នេះ ត្រូវក្រាលផេះ និងលាមកសត្វពីលើ និងកាយ ឬច្របល់ឱ្យបានសព្វល្អ។ ស្រទាប់នេះមានកម្រាស់ប្រហែលជា១៥-៣០ ស.ម ។ អាចដាក់ជីកំប៉ុស្តចាស់តិចទួចបន្ថែមទៀតពីព្រោះជាប្រភពដ៏ល្អនៃអតិសុខុមប្រាណដែលជួយបំបែកនូវសារធាតុសរីរាង្គទាំងនោះ។ មិនត្រូវសង្កត់ស្រទាប់នោះឱ្យហាប់ណែនឡើយប្រសិនបើគំនរជីកំប៉ុស្តនោះហាប់ណែនពេក ការរលួយមានភាពយឺតយ៉ាវ។






ការដាក់ផេះនិងដីលាមកសត្វកម្រាស់៣០ ស.ម នៅស្រទាប់ទី២

**ជំហានទី៧៖** បន្ថែមស្រទាប់ដីពីលើប្រហែល ២-៣ ស.ម ដើម្បីបន្តស្រទាប់ថ្មីបន្តទៀត ។ ត្រូវប្រាកដថាគ្មានដុំគ្រោះ ដុំថ្ម ដុំដីធំៗនិងដង្កុំឈើឡើយ។ ដីផ្ទុកនូវអតិសុខុមប្រាណ និងជួយពន្លឿនការបំបែកសារធាតុឱ្យរលួយបានឆាប់រហ័ស ព្រោះថាការងារនេះជាមូលដ្ឋានគ្រឹះសម្រាប់គំនរជី។





ការបន្ថែមដីលាមកសត្វ ដើម្បីជំរុញឱ្យឆាបរលួយ

**ជំហានទី៨៖** ស្រោចទឹកលើគនរជី ដោយរក្សាសំណើមឱ្យបានស្មើល្អ ជៀសវាងស្រោចជោកជាំពេក។ មិនត្រូវឱ្យមានទឹកហូរចេញឡើយ នៅពេលដែលយើងសង្កត់គំនរជី ការស្រោចទឹកត្រឹមត្រូវជាកិច្ចការសំខាន់ក្នុងការធ្វើជីកំប៉ុស្ត។





ការស្រោចទឹកពីលើគំនរជី

**ជំហានទី៩៖** អនុវត្តទម្រង់ដូចគ្នានេះចំនួន ៣ ដង ឬច្រើនជាងនេះឡើងវិញ ដើម្បីឱ្យគំនរជី មានកម្ពស់ខ្ពស់។ មិនត្រូវភ្លេចលំដាប់វាឡើយក្នុងនោះមាន ស្មៅ ស្លឹកឈើ ចំបើង ផេះ លាមកសត្វ ត្រូវជ្រោយឱ្យបានសព្វល្អ និងចុងក្រោយបង្អស់គឺដី។

**ជំហានទី១០៖** ក្រោយពីគរស្រទាប់រួចមក អ្នកនឹងទទួលបានគំនរជីមួយដែលមានកម្ពស់១,២ម៉ែត្រ ដើម្បីកុំឱ្យគំនរជីនេះស្ងួត ត្រូវគ្របស្រទាប់ស្មៅ ឬចំបើងពីលើដែលមានកម្រាស់ពី១០-១៥ស.ម។ ត្រូវទុកគំនរនោះចោលរយៈពេលពី៣-៤សប្តាហ៍ រយៈពេលដំបូងកម្ដៅក្នុងគំនរជី និងកើនឡើង ដោយសារដំណើរការបំបែកធាតុឱ្យ

រលួយដែលបណ្ដាលមកពីពពួកអតិសុខុមប្រាណ។ បន្ទាប់មកសីតុណ្ហភាពនឹងចុះត្រជាក់ជាលំដាប់មកវិញ។




*ការគ្របស្មៅ ឬចំបើងលើគំនរជី*

**ជំហានទី១១៖** យកឈើដែលបានសម្រួច ចាក់ចូលទៅក្នុងគំនរជីគ្រប់ទីកន្លែង ទុកចោលរយៈពេល ១០-១៥ នាទី បន្ទាប់មកត្រូវដកចេញ រួចស្ទាបមើលដើម្បីឱ្យដឹងថា ខាងក្នុងគំនរជីនោះមានកម្ដៅឬទេ។ បើមានកម្ដៅ ត្រូវទុកគំនរជីនោះបន្តទៀតរហូតដល់វាត្រជាក់។




*ការចាក់ឈើដែលមានចុងស្រួចដើម្បីពិនិត្យមើលកម្ដៅក្នុងគំនរជី*

**ជំហានទី១២៖** នៅពេលសីតុណ្ហភាពរបស់គំនរជីកុំប៉ុស្ដចុះត្រជាក់ ត្រូវត្រឡប់គំនរជី និងច្របល់សារធាតុទាំងអស់ឱ្យបានសព្វល្អ។ ត្រូវប្រាកដផងដែរថា គ្រប់សារធាតុទាំងអស់ ស្ថិតនៅស្រទាប់ខាងក្រៅពំនូកជី ត្រូវបានត្រឡប់មកស្រទាប់កណ្ដាលនៃគំនរជីថ្មីវិញ។

 

ការត្រឡប់ស្រទាប់ដីកំប៉ុស្ត

**ជំហានទី១៣៖** ជាថ្មីម្តងទៀត ត្រូវយកស្មៅគ្របគំនរជីនោះ ដើម្បីរក្សាសំណើម

 

ការគ្របស្មៅ ឬចំបើងលើគំនរជីសារជាថ្មី

**ជំហានទី១៤៖** ត្រួតពិនិត្យគំនរជីជាប្រចាំដើម្បីកុំឱ្យវាស្ងួត។ បើសិនមានសភាព ស្ងួត ត្រូវស្រោចទឹកពីលើ ដើម្បីរក្សាគំនរជីទាំងមូលឱ្យសើមជានិច្ច។

 

ការស្រោចទឹកលើគំនរជីកំប៉ុស្ត ពេលសង្កេតឃើញថាស្ងួត

**ជំហានទី១៥៖** បន្ទាប់ពីរយៈពេល១ខែ ត្រូវជីកត្រឡប់គំនរជីនោះ សារជាថ្មីម្តងទៀតនិងគ្របពីលើជាមួយស្លឹកត្នោត ឬស្មៅ។

រយៈពេល១ ខែបន្ទាប់មកទៀត ជីកំប៉ុស្តរបស់លោក អ្នកអាចយកទៅប្រើប្រាស់បាន។ ជីកំប៉ុស្តគេអាចប្រើប្រាស់ជាជីទ្រាប់បាត ដោយដាក់ពង្រាយ តាមស្រែឬចម្ការរួចភ្ជួរលប់ទៅក្នុងដីមុនពេលស្ទូង ព្រោះ ឬដាំដំណាំផ្សេងៗ។



ការគ្របស្មៅ ឬចំបើងលើគំនរជីសារជាថ្មី



ជីកំប៉ុស្តត្រូវយកទៅប្រើប្រាស់

## របៀបផលិតជីកំប៉ុស្តឆាប់បានប្រើប្រាស់

ពេលខ្លះដំណើរការនៃការបំបែកធាតុ ឱ្យរលួយមានភាពយឺតយ៉ាវ ដូច្នេះអ្នកអាចបង្កើនល្បឿនទៅលើដំណើរនៃការបំបែកសារធាតុទាំងនោះបានតាមមធ្យោបាយដូចតទៅ៖

លាយជីដែលមានសារធាតុអាសូតបន្ថែមខ្លះ ឬបន្ថែមសារធាតុដែលមានជាតិអាសូត្រច្រើនដូចជា៖ លាមកបសុបក្សី ស្មៅ រុក្ខជាតិអំបូរសណ្តែក ត្រូវកាត់ចិញ្ច្រាំទាំងដើម និងស្លឹក ឬកាកសំណល់បន្លែផ្សេងៗទៀតដាក់ទៅក្នុងគំនរជីកំប៉ុស្តរបស់យើង។

ជីកត្រឡប់ជីកំប៉ុស្ត ឱ្យបានទៀងទាត់ ដើម្បីឱ្យមានខ្យល់ចូល និងធ្វើឱ្យស្រទាប់មានសភាពធូរ និងត្រសុសល្អ។

## ៣. ការផលិតជីកំប៉ុស្តទឹក

ជីកំប៉ុស្តទឹក គឺជាល្បាយរាវខាប់ផ្ទាប់ ដែលអាចប្រើប្រាស់ធ្វើជាជី ឬផលិតសម្រាប់ថែទាំដំណាំ ដោយអាស្រ័យទៅលើ វត្ថុធាតុដើម ដែលមាននៅក្នុងជីនោះ។

### គោលដៅនៃការផលិតជីកំប៉ុស្តទឹក

- បង្កើនជីជាតិដី
- ជំរុញការបំបែកកាកសំណល់រុក្ខជាតិគ្របគល់ដំណាំ
- ការពារដំណាំពីសត្វល្អិត ពពួកបាក់តេរី និងកត្តាចង្រៃដទៃទៀត

### លក្ខខណ្ឌក្នុងការអនុវត្ត

- មានលាមកសត្វ ដូចជាលាមកបក្សី (មាន់ ទា ប្រចៀវ) លាមកជ្រូក លាមកគោ ក្របី ។ល។
- មានវត្ថុធាតុដើមជារុក្ខជាតិ ដូចជា៖
  - ទន្រ្ទានខែត្រ សម្រាប់គ្រប់គ្រងពពួកប៉ារ៉ាស៊ីត
  - ថ្នាំជក់ សម្រាប់គ្រប់គ្រងសត្វល្អិត
  - ស្លឹកស្ដៅសម្រាប់កម្ចាត់សត្វល្អិត
  - រុក្ខជាតិមានផ្លែជាកួរ (អង្គាដី កន្ទុំថេត អង្កាញ់ ម្រុំ) សម្រាប់បង្កើនធាតុអាសូត
- មានបាវ ធុងជ័រ ដុំថ្ម ឬពាងធ្វើពីដីដុត
- មានឈើមូលសម្រាប់កូរ

### ៣.១ វិធីសាស្រ្តនៃការផលិតជីកំប៉ុស្តទឹក

**ដំណាក់កាលទី១:** រកឱ្យបានធុង ឬពាងដែលអាចផ្ទុកទឹកបានតិចបំផុត១០០L

**ដំណាក់កាលទី២:** ច្រកចូលបាវមួយ នូវវត្ថុធាតុដើមខាងក្រោម៖

- ស្លឹកឈើចម្រុះ ១០ គ.ក្រ
- លាមកសត្វ ៦ គ.ក្រ





*ការផ្សំវត្ថុធាតុដើមធ្វើជីកំប៉ុស្តទឹក*

**ដំណាក់កាលទី៣:** ចាក់ទឹកចូលក្នុងធុង ឬពាងចំនួន១០០លីត្រ

**ដំណាក់កាលទី៤:** ទម្លាក់បាវដោយចងមាត់ជិតចូលទៅក្នុងពាង ឬធុងនោះហើយដាក់ដុំថ្មធំមួយសង្កត់ពីលើ ដើម្បីឱ្យលិចទៅក្នុងទឹកទាំងស្រុង

**ដំណាក់កាលទី៥:** បិទធុង ឬពាងវិញ ដោយប្រើគម្របដើម្បីការពាររុយ និងក្លិនស្អុយ ព្រមទាំងការពារសុវត្ថិភាព (គ្រោះថ្នាក់ទាក់ទងនឹងកុមារ) ផងដែរ។

**ដំណាក់កាលទី៦:** ក្នុងរយៈពេល២ ថ្ងៃ បន្ទាប់ពីដំណាក់កាលទី៥ អ្នកត្រូវកូរទឹកក្នុងធុង ឬពាងរយៈពេល២ នាទី ហើយចាក់ទឹកថែមទៀត ប្រសិនបើចាំបាច់(ដើម្បីឱ្យបាវជីលិចក្នុងទឹកជាប់រហូត)។ ត្រូវអនុវត្តដំណើរការបែបនេះ យ៉ាងតិចបំផុតមួយសប្តាហ៍ម្តង។

**ដំណាក់កាលទី៧:** បន្ទាប់ពី៣ ឬ ៦សប្តាហ៍(ដំណើរការផលិតនេះមានរយៈពេលមិនដូចគ្នាទេ ដោយផ្អែកទៅលើសីតុណ្ហភាពនៅខាងក្រៅ) ជីកំប៉ុស្តនេះគឺអាចយកទៅប្រើប្រាស់បានហើយ ដោយមានទឹកថ្លា និងគ្មានក្លិនឆ្អួល។ ជាធម្មតាជីកំប៉ុស្តអាចរក្សាទុកបានរយៈពេល១ខែ ដោយដាក់នៅកន្លែងដែលការពារ និងក្នុងម្លប់។




ការអនុវត្តកសិកម្មតាមបែបក្សេត្របរិស្ថាន

## ៣.២ ការប្រើប្រាស់ជីកំប៉ុស្តទឹក

✲ ប្រើផ្ទាល់ទៅលើដីដាំដុះ ស្រោចជីកំប៉ុស្តទឹកក្នុងអំឡុងពេល២ សប្តាហ៍ បន្ទាប់ពីស្ទូងឬដាំរួច ឬក្នុងអំឡុងពេល៣ សប្តាហ៍ បន្ទាប់ពីដុះពន្លក ឬនៅពេលចេញផ្កា ឬនៅពេលលេចចេញនូវសញ្ញាបង្ហាញពីកង្វះសារធាតុចិញ្ចឹម (ដំណាំមានពណ៌លឿងឬស្វាយ)។ ត្រូវលាយជាមួយនឹងទឹកពាក់កណ្ដាល( ៥០/៥០ )ហើយបរិមាណប្រើប្រាស់គឺ២,៥ - ៣ លីត្រ/ម² ឬ០,៣ លីត្រសម្រាប់ស្រោចចំគល់ឬរងដំណាំផ្ទាល់

តែម្តង។

⚛ ស្រោចលើស្លឹក(ជៀសវាងប្រើលើដំណាំទើបដាំ) ត្រូវលាយទឹកជី១/៤ នៃទឹក នៃជីកំប៉ុស្តទឹក ក្នុងបរិមាណទឹក ៣ទៅ៤ ដង ហើយស្រោចពី ១-២ លីត្រ/ម២ ដោយប្រើក្បាលផ្កាឈូកដែលមានរន្ធតូចៗ។

⚛ ជីកំប៉ុស្តទឹកអាចប្រើប្រាស់ជាជីជំនួយស្លឹក ដោយប្រើក្បាលបាញ់ស្រោចលើស្លឹក ហើយត្រូវច្រោះជីនេះ ដោយប្រើស្បៃនៅមុនពេលយកវាទៅប្រើ។ ជីកំប៉ុស្តទឹកនេះអាចស្រោចលើដំណាំជារៀងរាល់សប្តាហ៍រហូតដល់ចេញផ្កា។

## ៤. ការផលិតជីកំប៉ុស្តទ្រុង

### ៤.១ របៀបធ្វើទ្រុងជីកំប៉ុស្ត

គេអាចធ្វើទ្រុងជីកំប៉ុស្តបានពីរបៀប ដោយមានទំហំផ្សេងៗពីគ្នា

- ✓ ទ្រុងជីកំប៉ុស្តប្រភេទទី១ ទ្រុងតូច ទំហំ ១ម x ១ម x ១ម
- ✓ ទ្រុងជីកំប៉ុស្តប្រភេទទី២ ទ្រុងធំ ទំហំ ២ម x ១,៥ម x ១ម




ទ្រុងជីកំប៉ុស្តប្រភេទទី១ ទ្រុងជីកំប៉ុស្តប្រភេទទី២

## ក. ឧបករណ៍

បន្ទះរនាបឫស្សី ឬឈើទំហំ ៣ ស.ម -៤ ស.ម ដែកគោល កាំបិត ចបពូថៅ ញញួរ រណារ។










សម្ភារសម្រាប់ធ្វើទ្រុងដីកំប៉ុស្ត

## ខ. របៀបធ្វើទ្រុងដីកំប៉ុស្ត

កាត់បន្ទះរនាបឫស្សី ឬឈើគឺអាស្រ័យទៅតាមប្រភេទទ្រុងដែលយើងកំណត់

✓ វាយបន្ទះរនាបឫស្សី ឬឈើ ដោយទុកគម្លាតបន្ទះមួយទៅបន្ទះមួយទៀត ប្រមាណ ២ ស.ម។

✓ ធ្វើរបៀបនេះឱ្យបាន បួនផ្ទាំងដើម្បីផ្គុំគ្នាឱ្យបានជាទ្រុងជីកំប៉ុស្ត



ទម្រង់ទ្រុងជីកំប៉ុស្ត

### គ. ទីតាំងទ្រុងជីកំប៉ុស្ត

✓ ទ្រុងជីកំប៉ុស្តត្រូវស្ថិតនៅក្រោមម្លប់ ( កុំឱ្យត្រូវកម្តៅថ្ងៃ ) ក្បែរប្រភពទឹកឬក្បែរទ្រុងសត្វ។

### ឃ. ការតំឡើងទ្រុងជីកំប៉ុស្ត

- ✓ ត្រូវកាប់បំផុសដី បាតទ្រុងកំប៉ុស្តដើម្បីឱ្យមានខ្យល់ចេញចូល
- ✓ ត្រូវដាក់បង្គោលមូលទំហំពី ៨-១០ ស.ម ចំកណ្តាលសម្រាប់កំប៉ុស្តទ្រុងតូច
- ✓ ត្រូវដាក់បង្គោលចំនួន៣ សម្រាប់កំប៉ុស្តទ្រុងធំ
- ✓ ផ្គុំផ្ទាំងទ្រុងទាំង៤ ដោយចងខ្សែ



ទ្រុងដីកំប៉ុស្តពេលដំឡើងរួច

ង. វត្ថុធាតុដើមត្រូវយកមកផ្សំ

- ✓ លាមកសត្វដូចជា គោ-ក្របី មាន ទារ ជ្រូក....
- ✓ វត្ថុធាតុស្រស់ដូចជា ស្មៅ ដើមចេក កាកសំណល់ផ្ទះបាយ ទន្រ្ទានខេត្រ
- ✓ វត្ថុធាតុស្ងួតដូចជា ស្មៅក្រៀម ចំបើង សំបកពោត.............។





វត្ថុធាតុដើមសម្រាប់ផ្សំធ្វើដីកំប៉ុស្ត

### ច. ការរៀបចំវត្ថុធាតុដើម

✔ រៀបចំវត្ថុស្ងួតដែលបានចិញ្ច្រាំហើយ កម្រាស់ ២៥ ស.ម រួចស្រោចទឹកឱ្យជោគ និងជាន់បង្ហាប់។

✔ រៀបចំវត្ថុធាតុស្រស់ដែលបានចិញ្ច្រាំកម្រាស់១០ ស.ម-១៥ ស.ម ដោយចាក់ទឹកផ្សើមតិចៗ។

✔ ដាក់លាមកសត្វកម្រាស់១០ ស.ម

✔ អាចដាក់ផេះ ពីលើលាកមសត្វកម្រាស់០,៥ ស.ម - ១ ស.ម

✔ ធ្វើរបៀបនេះរហូតដល់ពេញទ្រុង

✔ បន្ទាប់ពីរៀបចំវត្ថុធាតុដើមពេញទ្រុងហើយ ដកបង្គោលចេញដើម្បីឱ្យមានរន្ធខ្យល់

✔ ត្រូវបន្តការស្រោចទឹក ឬទឹកនោមជ្រូកឱ្យគ្រប់គ្រាន់

✔ ការធ្វើជីកំប៉ុស្តនៅរដូវវស្សាឆាប់រលួយជាង រដូវប្រាំង។



ការរៀបចំវត្ថុធាតុដើមដាក់ក្នុងទ្រុងកំប៉ុស្ត

## ឆ. រយៈពេលជីកំប៉ុស្តអាចប្រើប្រាស់បាន

✓ ជីកប៉ុស្តទ្រុងតូច ជាធម្មតា ៤៥-៥០ ថ្ងៃក្រោយការរៀបចំរួច។ ក៏ប៉ុន្តែត្រូវជ្រោយត្រឡប់ ៧-១០ ថ្ងៃម្តង។




ជីកំប៉ុស្តទ្រុងតូច

✓ ជីកំប៉ុស្តទ្រុងធំរយៈពេលពី២-៣ ខែ និងប្រើប្រាស់បាន

✓ ការធ្វើជីកំប៉ុស្តទ្រុងធំនេះ មិនចាំបាច់ជ្រោយត្រឡប់ទេ តែទាមទារឱ្យធ្វើការស្រោចទឹក ឬ ទឹកនោមជ្រូកជាប្រចាំ (ក្នុងរយៈពេល៥-៧ថ្ងៃម្តង)







ជីកំប៉ុស្តទ្រុងធំ

ជ. ការសម្គាល់ជីកំប៉ុស្តអាចប្រើបាន៖

- ✓ សម្បុរពណ៌ត្នោតក្រម៉ៅ
- ✓ កម្តៅថយចុះជាធម្មតា
- ✓ មិនមានក្លិន
- ✓ មានសត្វដូចជា ជន្លេន ដង្កូវដួង រស់នៅក្នុងនោះ
- ✓ មានគ្រាប់រុក្ខជាតិអាចដុះចេញពីកំប៉ុស្តបាន





*ដំណាក់កាលជីកំប៉ុស្តទុំងរអាចយកទៅប្រើបាន*

ឈ. ការប្រើប្រាស់ជីកំប៉ុស្ត

- ✓ ប្រើលាយជាមួយដី សម្រាប់សាប និងផ្សាំកូនបន្លែក្នុងកន្ទោង
- ✓ ប្រើជាប្រភេទជីទ្រាប់បាត ៣០០ គ.ក្រ លើផ្ទៃដី ១០០ ម២
- ✓ នៅពេលប្រើត្រូវគ្រឡប់ ឬរាស់លុបឱ្យសព្វចូលក្នុងដី ដើម្បីជៀសវាងការហើរជី អាសូតដែលមាននៅក្នុងជីកំប៉ុស្ត។





## ៥. ការផលិតថ្នាំថ្នាំកសិកម្មធម្មជាតិ

ថ្នាំកសិកម្មធម្មជាតិ គឺជាការផ្សំសមាសធាតុ ទាំងឡាយណាដែលមានប្រភពមកពីធម្មជាតិ ហើយអាចបណ្តេញ ឬកម្ចាត់កត្តាចង្រៃ រួមទាំងសត្វល្អិត និងជំងឺហើយជាពិសេសនោះ គឺមិនប៉ះពាល់ដល់បរិស្ថាន។

រុក្ខជាតិ៤ ប្រភេទត្រូវបានជ្រើសរើសយកមកផលិតថ្នាំកសិកម្មធម្មជាតិ រួមមានពពួករុក្ខជាតិឆ្អួល ឬក្រពុល ល្វីង ហិល និងពុល។

**ឧទាហរណ៍:** ប្រភេទរុក្ខជាតិ ដែលមានផ្ទុកសារធាតុ

- ✔ ក្រពុល មានដូចជា សំបកទៀប ទន្រ្ទាំងខេត្រ ផ្កាស្បៃរឿង ក្រូចសើចនិងពពួកជីគ្រប់ប្រភេទ
- ✔ ហិល មានដូចជា ម្ទេស រំដេង ពពួកខ្ញី
- ✔ ល្វីង មានដូចជា ស្តៅ បណ្តូលពេជ្រ
- ✔ ពុល មានដូចជា ថ្នាំជក់ គ្រាប់ស្លែង ក្តួច ផ្លែស្លាក់ សំបកកន្ទួត ។ល។

រុក្ខជាតិក្រពុល និងហិល មានតួនាទី បណ្តេញ រីឯរុក្ខជាតិល្វីងហើយនឹងពុលមានតួនាទីសម្លាប់សត្វល្អិតចង្រៃ។

### ៥.១ រុក្ខជាតិដែលអាចយកមកផ្សំជាថ្នាំកសិកម្មធម្មជាតិមាន៖

១. ក្តួច គ្រាប់ស្លែង ឬផ្លែស្លាក់ ចំនួន ៦ គីឡូក្រាប

២. សំបកកន្ទួត ចំនួន ១០ គីឡូក្រាម

៣. ថ្នាំជក់ ចំនួន ២ គីឡូក្រាម

៤. ទន្រ្ទាំងខេត្រ ចំនួន ៦ គីឡូក្រាម

៥. សំបកទៀប ចំនួន ៤ គីឡូក្រាម

៦. វល្លិ៍មាស ឬផ្កាស្បៃរឿង ចំនួន ៤ គីឡូក្រាម

៧. សំបកស្តៅ ចំនួន ១០ គីឡូក្រាម

៨. បណ្តូលពេជ្រចំនួន ៦ គីឡូក្រាម

៩. ម្ទេសចំនួន ២ គីឡូក្រាម

១០. រំដេងចំនួន ៣ គីឡូក្រាម

១១. ទឹកនោម ចំនួន ៣០-៥០ លីត្រ



វល្លិ៍មាស



ដើម និងមើមរំដេង



មើមរំដេង



ដើមទៀបបាយ



ដើមកន្ទួត



ទឹកនោម



ស្លឹកក្បៀស



ផ្លែស្លែង



ម្ទេស



ថ្នាំជក់



ដើមទន្ទ្រានខេត្ត

## វិធីផ្សំ

- ✔ ចិញ្ច្រាំរុក្ខជាតិទាំងអស់ឱ្យម៉ដ្ឋ
- ✔ ដាក់វាទៅក្នុងពាងដែលមានចំណុះទឹក ២០០ លីត្រ
- ✔ ចាក់បន្ថែមទឹកនោម ៣០-៥០ លីត្រ ហើយកូល្បាយនោះឱ្យសព្វសាច់ល្អ បន្ទាប់មកគ្របពាងឱ្យជិត។
- ✔ ធ្វើការកូល្បាយ១ថ្ងៃម្តង រៀងរាល់ថ្ងៃ ម្តងៗរយៈពេល៥នាទី
- ✔ ផ្អាប់វាទុកក្នុងម្លប់រយៈពេលពី ១៥-២០ ថ្ងៃទើបមានប្រសិទ្ធភាពល្អ។



ការចិញ្ចាំរុក្ខជាតិ



ការកូឈ្សាយរុក្ខជាតិ

## សារៈប្រយោជន៍នៃការប្រើប្រាស់ថ្នាំកសិកម្មធម្មជាតិ

- ✔ មិនប៉ះពាល់ដល់សុខភាព
- ✔ មិនចាំបាច់ចំណាយថវិកាច្រើន
- ✔ ដំណាំមានតម្លៃនៅលើទីផ្សារ
- ✔ អ្នកប្រើប្រាស់និយមចូលចិត្តទិញ
- ✔ វត្ថុធាតុដើមអាចរកបានក្នុងតំបន់

រុក្ខជាតិនីមួយៗមានប្រសិទ្ធភាព លើសត្វល្អិតផ្សេងៗគ្នា ដូច្នេះយើងអាចផលិតថ្នាំកសិកម្មធម្មជាតិ ដោយប្រើរុក្ខជាតិមួយចំនួន ដែលអាចរកបាន ដោយមិនចាំបាច់គ្រប់មុខឡើយ។



## ៥.២ វិធីប្រើប្រាស់ថ្នាំកសិកម្មធម្មជាតិ

✓ លាយល្បាយចម្រុះថ្នាំកសិកម្មធម្មជាតិ ១ លីត្រជាមួយទឹក ១៥ លីត្រ សមាមាត្រថ្នាំកសិកម្មធម្មជាតិ ផ្អែកទៅលើភាពពិតជាក់ស្តែង របស់សត្វល្អិតចង្រៃដែលមាននៅក្នុងសួន ឬចម្ការ ។ បន្ថែមសាប៊ូម្សៅ ១ កូនស្លាបព្រាកាហ្វេរ រួចកូរឱ្យសព្វ ដើម្បីបង្កើនប្រសិទ្ធភាពថ្នាំ។

✓ បាញ់ថ្នាំនេះចំនួន ២ ឬ ៣ ដង ក្នុងមួយសប្តាហ៍ ហើយការបាញ់គម្បីធ្វើឡើងនៅពេលថ្ងៃរៀបលិច។

✓ ត្រូវអនុវត្តយ៉ាងប្រុងប្រយ័ត្ន នៅពេលបាញ់ថ្នាំ ដូចជាត្រូវពាក់ខោ អាវដៃវែង ស្រោមដៃ ម៉ាស់ការពារមុខ ពាក់មួក វ៉ែនតា ស្បែកជើងកវែង ។ល។៕



# ឯកសារយោង:


១. ការធ្វើជីកំប៉ុស្តជាលក្ខណៈគ្រួសារ ការិយាល័យកែលម្អដីកសិកម្ម, ២០១៥

២. ព្រឹត្តិបត្របច្ចេកទេសស្តីពីជីកំប៉ុស្ត គម្រោងជួយដោះស្រាយភាពងាយរងគ្រោះនៅតាមជនបទ និងស្ថិរភាពប្រព័ន្ធអេកូឡូស៊ី (កម្ពុជាហាវែស), ២០១៣

៣. បច្ចេកទេសផលិតជីកំប៉ុស្ត គម្រោងបង្ហាញបច្ចេកវិទ្យាបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD TA 7305-CAM)

៤. ព្រឹត្តិបត្រព័ត៌មានកសិករស្តីពីការធ្វើជីកំប៉ុស្ត វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា

៥. ឯកសារស្តីពីការផលិតជីកំប៉ុស្តទឹក facebook.com/SOPHALLETH

៦. បទបង្ហាញស្តីពីការធ្វើកំប៉ុស្តគោគ និងកំប៉ុស្តទឹក និងការផលិតថ្នាំពុលសរីរាង្គ ឬធម្មជាតិពីរុក្ខជាតិ Presented by Sang Kung on, ២០១៣៕






**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៤៥

**ទូរសារលេខ** : (៨៥៥)២៣ ២១០ ៩៤៨

**Facebook** : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម - **Department of Agricultural Extension**

**គេហទំព័រ** : **http://www.maff.gov.kh**